PICAC NT
Partners in Culturally Appropriate Care

# ការចុះហត្ថលេខាលើកិច្ចសន្យាសម្រាប់សេវាកម្មថែទាំតាមផ្ទះ




## កញ្ចប់សេវាកម្មថែទាំតាមផ្ទះ (Home Care Package) អាចធានាថាអ្នកទទួលបានសេវាកម្មផ្សេងៗ និងការគាំទ្រដែលអ្នកត្រូវការចាំបាច់។

មុនពេលអ្នកចុះកិច្ចសន្យាជាមួយអ្នកផ្តល់សេវាកម្មណាមួយដើម្បីផ្តល់សេវាកម្មថែទាំតាមផ្ទះ វាជាប្រការសំខាន់ដែលអ្នកដឹងពីសិទ្ធិ និងការទទួលខុសត្រូវរបស់អ្នក។

## អ្នកចាំបាច់ត្រូវ៖

1. យល់ដឹងពីសិទ្ធិរបស់អ្នក[1]។
2. ដឹងថាសិទ្ធិរបស់អ្នកត្រូវតែបានគោរពដោយអ្នកផ្តល់សេវាកម្មថែទាំតាមផ្ទះ។
3. ប្រសិនបើអ្នកមានការព្រួយបារម្ភផ្សេងៗ ចូរនិយាយទៅកាន់អ្នកផ្តល់សេវាកម្មរបស់អ្នក។
4. អ្នកមានការទទួលខុសត្រូវលើអ្នកផ្តល់សេវាកម្មថែទាំតាមផ្ទះដែលអ្នកជ្រើសរើស។
5. ត្រូវចេះគោរព និងចេះគិតដល់អ្នកដទៃ។
6. ផ្តល់កន្លែងមានសុវត្ថិភាពដល់អ្នកផ្តល់សេវាកម្ម និងបុគ្គលិករបស់ពួកគេដើម្បីជួយអ្នក។
7. ត្រូវមានចិត្តទូលាយក្នុងការផ្លាស់ប្តូរកញ្ចប់សេវាថែទាំតាមផ្ទះ (Home Care Package) ប្រសិនបើសុខភាពរបស់អ្នកប្រែប្រួល។
8. បង់ថ្លៃសេវាថែទាំតាមផ្ទះដូចដែលបានយល់ព្រមជាមួយអ្នកផ្តល់សេវាកម្មរបស់អ្នក។

[1]Home Care Packages Program Manual for Care Recipients, (សៀវភៅកម្មវិធីកញ្ចប់សេវាថែទាំតាមផ្ទះសម្រាប់អ្នកទទួលការថែទាំ) កំណែ ថ្មី 1.4, ខែ មករា 2023


COTA
NORTHERN TERRITORY
for senior Territorians

(08) 8941 1004
www.cotant.org.au/picac/contact-picac-nt

PICAC NT
Partners in Culturally Appropriate Care

# ការចុះហត្ថលេខាលើកិច្ចសន្យាសម្រាប់សេវាកម្មថែទាំតាមផ្ទះ

## មុនពេលអ្នកចុះហត្ថលេខាលើកិច្ចសន្យា

**អ្នកមានសិទ្ធិនានា មុន ពេលចុះហត្ថលេខាលើកិច្ចសន្យា។ អ្នកត្រូវតែយល់ដឹងឲ្យបានច្បាស់លើកិច្ចសន្យាដែលអ្នកនឹងចុះហត្ថលេខា។**

### ចំណុចនានាដែលត្រូវពិនិត្យ

| | | បាទ/ចាស | ទេ |
|---|---|---|---|
| 1. | តើអ្នកទទួលបានច្បាប់ចម្លងកិច្ចសន្យា ក្រដាសព័ត៌មាន ឬខិត្តប័ណ្ណអំពីសេវាកម្មដែលផ្តល់ជូនជាភាសាអង់គ្លេសងាយយល់ និងគ្មានពាក្យបច្ចេកទេសទេ? | ☐ | ☐ |
| 2. | តើអ្នកទទួលបានច្បាប់ចម្លងនៃឯកសារទាំងអស់ជាភាសាខ្មែរ ដែលផ្តល់ជូនដោយអ្នកផ្តល់សេវាកម្មរបស់អ្នកទេ? | ☐ | ☐ |
| 3. | តើអ្នកទទួលបានកិច្ចសន្យាមួយច្បាប់ (ទាំងភាសាអង់គ្លេស និងខ្មែរ) យ៉ាងហោចណាស់មួយសប្តាហ៍មុនពេលណាត់ជួបដើម្បីចុះហត្ថលេខាទេ? * | ☐ | ☐ |
| 4. | តើកិច្ចសន្យារួមមានបញ្ជីច្បាស់លាស់នៃសេវាកម្មនានាពីអ្នកផ្តល់សេវាកម្មដែលនឹងផ្តល់ជូនពេលអ្នកចុះហត្ថលេខាទេ? | ☐ | ☐ |
| 5. | តើកិច្ចសន្យាមានរៀបរាប់ពីសេវាកម្មនានាដែលអាចនឹងផ្តល់ជូនដោយអ្នកផ្តល់សេវាកម្មដោយផ្អែកលើការវាយតម្លៃលើការថែទាំតាមផ្ទះរបស់អ្នកទេ (ទោះបីពេលនេះអ្នកមិនចាប់អារម្មណ៍ចំពោះសេវាកម្មទាំងនោះក៏ដោយ)? | ☐ | ☐ |
| 6. | តើអ្នកបានពិចារណាពីវិធីដែលអ្នកពេញចិត្តសម្រាប់ការទូទាត់ប្រាក់ទេ (ដូចជាការដកប្រាក់ផ្ទាល់ចេញពីគណនីធនាគារ ការកាត់ប្រាក់ចេញពី Centrelink ឬការផ្ទេរប្រចាំខែ)? | ☐ | ☐ |
| 7. | តើគេមានផ្តល់ជូនអ្នកបកប្រែផ្ទាល់មាត់ដែលមានជំនាញ ក្រៅពីសមាជិកគ្រួសារ ដើម្បីផ្តល់ការបកប្រែពេលធ្វើការសន្ទនាជាមួយអ្នកផ្តល់សេវាកម្មទេ?* | ☐ | ☐ |
| 8. | តើអ្នកមានពេលវេលាក្នុងការពិនិត្យមើលកិច្ចសន្យាជាមួយអ្នកផ្តល់សេវាកម្ម ហើយទទួលបានចំឡើយលើសំណួរទាំងអស់របស់អ្នកទេ? | ☐ | ☐ |
| 9. | តើអ្នកទទួលបានច្បាប់ចម្លងធម្មនុញ្ញនៃសិទ្ធិថែទាំមនុស្សចាស់ជាភាសាខ្មែរ ក្រៅពីភាសាអង់គ្លេសទេ? | ☐ | ☐ |

**ប្រសិនបើអ្នកឆ្លើយថា ‘ទេ’ លើចំណុចណាមួយក្នុងចំណោមចំណុចទាំងនេះ អ្នកមានសិទ្ធិសួរអ្នកផ្តល់សេវាកម្មរបស់អ្នកដើម្បីស្វែងយល់ពីព័ត៌មានបន្ថែម។**

* សេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ដែលមានវិជ្ជាជីវៈ **មិនគិតថ្លៃ** សម្រាប់អ្នក និងអ្នកផ្តល់សេវាកម្ម។

ការបោះពុម្ពផ្សាយនេះបានបង្កើតឡើងដោយ COTA NT គាំទ្រដោយការរួមចំណែកផ្នែកហិរញ្ញវត្ថុពីក្រសួងសុខាភិបាល និងថែទាំមនុស្សចាស់ (Department of Health and Aged Care)។ ដើម្បីទទួលបានឯកសារដែលអាចកែសម្រួលបាន សូមទាក់ទងអ្នកគ្រប់គ្រង PICAC។

COTA NORTHERN TERRITORY
for senior Territorians

(08) 8941 1004
www.cotant.org.au/picac/contact-picac-nt